# មេរៀនទី ៨

# ការជម្លៀស និង ការគ្រប់គ្រងទីកន្លែងជម្លៀស

## Module 8

## Evacuation and Evacuation Center Management

# អ្វីជាការជម្លៀស?

ការជម្លៀស ជាការចលនា ឬ ការចាកចេញរបស់មនុស្ស សត្វ និង ទ្រព្យសម្បត្តិពីកន្លែងដែលមានគំរាមកំហែង ដោយមុខសញ្ញាបង្កគ្រោះថ្នាក់ ទៅកាន់ទីកន្លែងដែលមានសុវត្ថិភាព ។

ការជម្លៀង មានទំរង់ដូចជា :

- ជនរងគ្រោះជម្លៀសដោយខ្លួនឯង (ចំពោះមុខសញ្ញាបង្កគ្រោះថ្នាក់ណាដែលមានល្បឿន យឺត)
- ដោយមានការជួយពីអ្នកជិនខាង (ចំពោះមុខសញ្ញាបង្កគ្រោះថ្នាក់ណាដែលមានល្បឿន យឺត)
- តំរូវអោយអាជ្ញាធរ និង ក្រុមទទួលខុសត្រូវជួយអន្តរាគមន៍ជួយ (មុខសញ្ញាបង្កគ្រោះថ្នាក់ណាដែលមាន ល្បឿនលឿន ហើយមានឥទ្ធិពលខ្លាំងខុសពីធម្មតា)



# មូលហេតុអ្វីបានជាធ្វើការជម្លៀស?

- ដោយមានពតិមានពីការព្យាករណ៍ និង ការប្រកាសភាពអាសន្ន ( ការផ្តល់ពតិមានអោយដឹងជាមុន )
- ដោយស្ថានភាពជាក់ស្តែងនៅកន្លែងដែលមានមុខសញ្ញាបង្កគ្រោះថ្នាក់បានកើតឡើង
- តំរូវការរបស់ប្រជាជនដែលកំពុងប្រឈមមុខ សុំអោយអោយអាជ្ញាធរ ស្ថាប័ន និង ក្រុមទទួលខុសត្រូវជួយពួកគេអោយរួចផុតពីគ្រោះថ្នាក់

# កត្តាដែលធានាធ្វើអោយការជម្លៀសមានប្រសិទ្ធិភាព និង ទាន់ពេលវេលា

- រៀបចំផែនការជម្លៀស ( អ្នកណាទទួលខុសត្រូវ មធ្យោបាយ នៅពេលណា.............)
- កំនត់ទីទួលសុវត្ថិភាពដែលតំរូវជម្លៀសទៅកាន់
- កំនត់ផ្លូវដែលនៅជិន និង មានសុវត្ថិភាព ដោយដាក់សញ្ញាចង្អុលទិស
- កំនត់សញ្ញា ឬ សំលេងណាមួយសំរាប់ប្រកាសភាពអាសន្ន ដែលស**ញ្ញានោះ ត្រូវបានឯកភាពគ្នា និង ប្រជាពលរដ្ឋបានដឹងគ្រប់ ៗ គ្នា**

# អ្វី

- រៀបចំបញ្ជីរឈ្មោះ អ្នកណា  ឬ គ្រួសារណាដែលទំនងជាត្រូវជម្លៀស
- រៀបចំឧបករណ៍-សំភារៈ បំរុងទុកសំរាប់ទទួលជនរងគ្រោះ នៅលើទីទួលសុវត្ថិភាព
- រៀបចំការគ្រប់គ្រងទីកន្លែងដែលប្រជាពលរដ្ឋជម្លៀសមកកាន់
  (ទីទួលសុវត្ថិភាព)....កន្លែងសំរាប់មនុស្ស  ....សត្វ......ជំរក.....បង្គន់.....ប្រព័ន្ធទឹកស្អាត....

# ការគ្រប់គ្រងគ្រោះមហន្តរាយ “ទឹកជំនន់”

ជាបណ្តុំនៃវិធានការ ឬ សកម្មភាព ដែលគេរៀបចំឡើង ដើម្បីអនុវត្តនាំង មុនពេល ក្នុងពេល និង ក្រោយពេល មានគ្រោះមហន្តរាយកើតឡើង សំដៅកាត់បន្ថយផលប៉ះពាល់អោយមានប្រសិទ្ធិភាព ទាន់ពេល និង កំរិតប៉ះពាល់តិចតួចបំផុត ។ វិធានការរួមមាន ត្រៀមបង្ការ ការពារ កាត់បន្ថយ ឆ្លើយតប សង្គ្រោះបន្ទាន់ និង ស្តារ ឬ ជួសជុលឡើងវិញ។

# មូលហេតុអ្វីបានជាត្រូវធ្វើការងារគ្រប់គ្រងគ្រោះមហន្តរាយ “ទឹកជំនន់”

*គេថា“ មិនចាំបាច់ធ្វើការងារគ្រប់គ្រងគ្រោះ ទឹកជំនន់ ធ្វើអ្វី បើប្រជាជនធ្លាប់រស់នៅ ជាមួយទឹកជំនន់ តាំងពីដូនតាគេមកម្លេះ ”*

*គេថា“ មិនចាំបាច់ធ្វើការងារគ្រប់គ្រងគ្រោះ ទឹកជំនន់ ធ្វើអ្វី ព្រោះប្រជាជន នៅតាម ដងទន្លេចង់បានតែទឹកធំ ងាយស្រួល ក្នុង ការបង្កបង្កើតផល និង ផលដំណាំ បានកើនឡើង ”*



# មូលហេតុអ្វីបានជាត្រូវធ្វើការខារគ្រប់គ្រងគ្រោះមហន្តរាយ “ទឹកជំនន់”



# ការវិភាគលើដំណាក់កាលនៃការគ្រប់គ្រងគ្រោះមហន្តរាយ “ទឹកជំនន់”




**តាមបទពិសោធន៍របស់លោក-អ្នក តើដំណាក់កាលណាមួយសំខាន់ និង ចាំបាច់ នៅក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ “ទឹកជំនន់” ?**

# ដំណាក់កាលមុនគ្រោះមហន្តរាយ

## ការការពារ

ជាវិធានការសំរាប់ការពារជាអចិន្ត្រៃយ៍ ដើម្បីទប់ស្កាត់ មិនអោយមុខសញ្ញាគ្រោះថ្នាក់កើតឡើង ឬ កុំអោយមុខសញ្ញាគ្រោះថ្នាក់ក្លាយជាគ្រោះមហន្តរាយ ។ វិធានការមានពីរបែបសំខាន់ ៗ គឺ :

- បែបហេដ្ឋារចនាសម្ព័ន្ធ (ទំនប់ ប្រឡាយ..)
- បែបមិនមែនហេដ្ឋារចនាសម្ព័ន្ធ (អប់រំ ផ្សព្វផ្សាយ រៀបចំគោលនយោបាយ.......ល)




ការការពារគ្រោះមហន្តរាយ

# ដំណាក់កាលមុនគ្រោះមហន្តរាយ




ការកាត់បន្ថយគ្រោះមហន្តរាយ

## ការកាត់បន្ថយ

ជាវិធានការដែលគេធ្វើទាំងមុនពេល និង ក្នុងពេលមានមុខសញ្ញាគ្រោះថ្នាក់កើតឡើង ដើម្បីកាត់បន្ថយឥទ្ធិពល និងផលប៉ះពាល់របស់មុខសញ្ញាបង្កគ្រោះថ្នាក់ ។ វិធានការនេះក៏អាចធ្វើបានតាមពីរបែបសំខាន់ដែរគឺ :

១. បែបហេដ្ឋារចនាសម្ព័ន្ធ (ទប់ទំនប់ ដាក់បាវខ្សាច់ ....)

២. មិនមែនហេដ្ឋារចនាសម្ព័ន្ធ (អប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាល...........)

# ដំណាក់កាលមុនគ្រោះមហន្តរាយ

## ការត្រៀមបង្ការ

ជាបណ្តុំនៃវិធានការនានា ដែលគេបានរៀបចំទុកជាមុន មុនពេលមានមុខសញ្ញាគ្រោះថ្នាក់កើតឡើង

*ដើម្បីធានា ធ្វើអោយការឆ្លើយប និងសង្គ្រោះ អនុវត្តមានប្រសិទ្ធិភាព និង ទាន់ពេលវេលា នៅពេលណាដែលមានមុខសញ្ញាគ្រោះថ្នាក់កើតឡើង ។*



# ដំណាក់កាលមុនគ្រោះមហន្តរាយ

- **ការផ្សព្វផ្សាយ និង បង្កើនការយល់ដឹង**

ជាវិធានការត្រៀមបង្ការមួយ ដែលគេត្រូវធ្វើសំដៅបង្កើន ការយល់ដឹងដល់ប្រជាជន ដែលរស់នៅតំបន់ប្រឈមមុខនឹង មុខសញ្ញាគ្រោះថ្នាក់ ដើម្បីអោយគេបានយល់ដឹងពីមុខសញ្ញា គ្រោះថ្នាក់ ឥទ្ធពលរបសវា ពេលវេលាដែលវាកើត គ្រោះថ្នាក់ជាយថាហេតុដែលអាចគំរាមកំហែង និង ដើម្បីអប់រំ ផ្សព្វផ្សាយពីវិធានការសមស្រប ក្នុងការត្រៀមជាមុន ដើម្បី ការកាត់បន្ថយផលប៉ះពាល់ដល់អាយុជីវិតហេដ្ឋារចនាសម្ព័ន្ធ



# ដំណាក់កាលមុនគ្រោះមហន្តរាយ

- **ការបណ្តុះបណ្តាល និង ការបង្កើនសមត្ថភាព**

ជាការពង្រឹង ឬ បង្កើនសមត្ថភាពដល់ស្ថាប័ន អាជ្ញាធរ មូលដ្ឋាន និង ក្រុមដែលទទួលខុសត្រូវ ដើម្បីអោយគេ អាចមានសមត្ថភាព ចំណេះដឹង លទ្ធភាពគ្រប់គ្រាន់ ក្នុងការអនុវត្តន៍ការងារ ។ ចំនុចសំខាន់ នៃការបណ្តុះបណ្តាល ត្រូវធ្វើយ៉ាងណា អោយវាអាចឆ្លើយតបនឹងសេចក្តីត្រូវការរបស់អ្នក អនុវត្តការងារជាក់ស្តែង ពោលគឺចំណេះដឹង និង បទពិសោធន៍ជាក់ស្តែង ។



# ដំណាក់កាល កំពុងមានគ្រោះមហន្តរាយ

- **ការឆ្លើយតប និង សង្គ្រោះបន្ទាន់**

ជាវិធានការបន្ទាន់ និង ចាំបាច់ត្រូវធ្វើនៅពេលដែលមុខសញ្ញាគ្រោះថ្នាក់បានកើតឡើង ដើម្បីបញ្ចៀស និង កាត់បន្ថយ ផលប៉ះពាល់ និង បាត់បង់អាយុជីវិតមនុស្ស សត្វ និង ទ្រព្យសម្បត្តិ អោយមានកំរិតតិចតួច ។ វិធានឆ្លើយតប និង សង្គ្រោះ រួមមាន ៖

  - ការស្រាវជ្រាវ និង រុករកសង្គ្រោះ
  - ការជម្លៀស
  - ការផ្តល់ពតិមានជាមុនពីគ្រោះថ្នាក់
  - ការផ្តល់ជំរក
  - ការផ្តល់ទឹកស្អាត
  - ស្បៀងអាហារ




ការឆ្លើយតបគ្រោះមហន្តរាយ

# ដំណាក់កាល កំពុងមានគ្រោះមហន្តរាយ

- **ព្យាករណ៍ និង ការផ្ដល់ពត៌មានជាមុន**

ជាវិធានការដែលគេធ្វើដើម្បីផ្ដល់ពតិមានស្ដីពីការកើតឡើងនៃមុខសញ្ញាគ្រោះថ្នាក់ ដូចជា ពេលវេលាដែលវាកើត ឥទ្ធិពល ល្បឿន ផលប៉ះពាល់របស់វា ដល់ស្ថាប័នអាជ្ញាធរមូលដ្ឋាន ក្រុមទទួលខុសត្រូវ និង ប្រជាជនដែលនៅតាមតំបន់ប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់ ដើម្បីអោយធ្វើការប្រុងប្រយ័ត្ន ត្រៀមវិធានឆ្លើយតប និង ទប់ស្កាត់ទៅនឹងស្ថានភាពជាក់ស្ដែង ។



# ដំណាក់កាល កំពុងមានគ្រោះមហន្តរាយ



- **ស្រាវជ្រាវ និង រុករកសង្គ្រោះ**

ជាវិធានការស្រាវជ្រាវ និង រុករកសង្គ្រោះជនរងគ្រោះដែលរស់នៅតំបន់ដែលទទួលរងគ្រោះថ្នាក់ ឬ ការស្វែងរកជនរងគ្រោះដែលបាត់ខ្លួន ក្នុងពេល និង ក្រោយពេលគ្រោះមហន្តរាយកើតឡើង។

- **ការជម្លៀស**

ជាការដឹកជញ្ជូន ឬ ការបញ្ជូនប្រជាជនដែលរស់នៅតំបន់ដែលមានការគំរាមកំហែងដោយមុខសញ្ញាគ្រោះថ្នាក់ ទៅដាក់នៅទីកន្លែងដែលមានសុវត្ថិភាព អាចរួចផុតពីគ្រោះថ្នាក់ផ្សេង ៗ



# ដំណាក់កាល  កំពុងមានគ្រោះមហន្តរាយ

- វិធានការកាត់បន្ថផលប៉ះពាល់គ្រោះមហន្តរាយ នៅពេលដែលមុខសញ្ញាគ្រោះថ្នាក់បានកើតឡើងហើយ





- វិធានការកាត់បន្ថយមុខសញ្ញាគ្រោះថ្នាក់ មិនទាន់បានកើតឡើង

# ដំណាក់កាល ក្រោយគ្រោះមហន្តរាយ

- **ការស្តារ ឬ ជួសជុលឡើងវិញ**

ជាវិធានការដែលគេធ្វើក្រោយពេលមានគ្រោះមហន្តរាយ ដើម្បីធ្វើអោយស្ថានភាពអាចវិលទៅរកភាពដើមប្រសើរឡើងវិញ ។ ការងារស្តារ និង ជួសជុលឡើងវិញ រួមមាន ការជួសជុលផ្លូវ ស្ពាន ប្រលាយទឹក ដាំដំណាំឡើងវិញ និង ធ្វើអោយដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រព្រឹត្តិទៅដូចដើមឡើងវិញ។



ការស្តារ ឬ ការស្តារឡើងវិញ